មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ការវិភាគលើសេចក្ដីព្រាងច្បាប់ទាំងបី
# ពាក់ព័ន្ធនឹងវិស័យតុលាការ

## ចងក្រងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

(បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយនឹងក្រុមអង្គការសង្គមស៊ីវិល ក្រុមអ្នកជំនួញ និងក្រុមប្រទេសម្ចាស់ជំនួយ)

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤

# មាតិកា


I. **សេចក្តីសង្ខេប** ........ 3

II. **សាវតារ** ........ 4

III. **ការវិភាគលើបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តន៍ល្អៗជាអន្តរជាតិ** ........ 6

**សេចក្តីព្រាងច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ........ 7

១. សេចក្តីព្រាងច្បាប់នេះបានដាក់បញ្ចូលអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] ទៅក្នុងរចនាសម្ព័ន្ធ ដំណើរការ និង ហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមានតួនាទីធានាឯករាជ្យភាពតុលាការ ........ 8

២. សេចក្តីព្រាងច្បាប់អនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានតែងតាំងដោយស្វ័យប្រវត្តិដោយមិនឆ្លងកាត់ការបោះឆ្នោតដោយស្ថាប័នមួយឯករាជ្យ ........ 13

**សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា** ........ 16

សេចក្តីព្រាងច្បាប់បានផ្តល់អំណាចឲ្យអំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] មានឥទ្ធិពលលើការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រម និង ព្រះរាជអាជ្ញា ........ 17

**សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ** ........ 18

១. សេចក្តីព្រាងច្បាប់បានផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ........ 19

២. សេចក្តីព្រាងច្បាប់បានផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ចាត់ចែងលើថវិការបស់សាលាជម្រះក្តីទាំងអស់ ........ 20

IV. **សេចក្តីសន្និដ្ឋាន** ........ 22

# ការវិភាគលើសេចក្តីព្រាងច្បាប់ទាំងបីពាក់ព័ន្ធនឹងវិស័យតុលាការ

## I. សេចក្តីសង្ខេប

ការវិភាគផ្លូវច្បាប់នេះ មានបំណងត្រួតពិនិត្យទៅលើកម្រិតអំណាចរបស់អង្គនីតិប្បញ្ញត្តិ និង អង្គនីតិប្រតិបត្តិ នៅក្នុងសេចក្តីព្រាងច្បាប់សំខាន់ៗចំនួន ៣ ដែលទាក់ទងទៅនឹងអំណាចតុលាការ គឺសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា និង សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[1]។ ក្រុមអង្គការសង្គមស៊ីវិល ក្រុមអ្នកវិនិយោគិន និងក្រុមប្រទេសម្ចាស់ជំនួយមានក្តីបារម្ភរួមគ្នាជាខ្លាំងចំពោះការធានាឯករាជ្យភាពនៃអំណាចតុលាការ បន្ទាប់ពីបានពិនិត្យមើលលើសេចក្តីព្រាងច្បាប់ទាំងបីនេះ ដោយហេតុថា គោលការណ៍ឯករាជ្យភាពតុលាការ ដែលជាគោលការណ៍មូលដ្ឋាននៃសង្គមប្រជាធិបតេយ្យ មិនអនុញ្ញាតឲ្យអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ជ្រៀតជ្រែក និង ជះឥទ្ធិពលដោយផ្ទាល់ ឬ ដោយប្រយោលមកលើអំណាចតុលាការ។ ការវិភាគនេះបានរកឃើញថា សេចក្តីព្រាងច្បាប់ទាំង ៣ ខាងលើ <u>ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍ឯករាជ្យរបស់តុលាការ</u> ដោយបាន៖

- ដាក់បញ្ចូលអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] ទៅក្នុងរចនាសម្ព័ន្ធ ដំណើរការ និង ហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមានតួនាទីធានាឯករាជ្យភាពតុលាការ។
- អនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានតែងតាំងដោយស្វ័យប្រវត្តិដោយមិនឆ្លងកាត់ការបោះឆ្នោតដោយស្ថាប័នមួយឯករាជ្យ។
- ផ្តល់អំណាចឲ្យអំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] មានឥទ្ធិពលលើការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រម និង ព្រះរាជអាជ្ញា។
- ផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់។
- ផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ចាត់ចែងលើថវិការបស់សាលាជម្រះក្តីទាំងអស់។

<u>អនុសាសន៍សំខាន់ៗ</u>៖

- អំណាចក្រសួងយុត្តិធម៌គួរតែត្រូវបានដកចេញពីរចនាសម្ព័ន្ធ ដំណើរការ និង ហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈការបង្កើតឲ្យមានសមាសភាពមួយដែលកើតចេញពីការបោះឆ្នោតជ្រើសរើសប្រកបដោយភាពតំណាង ដោយចៅក្រម និង ព្រះរាជ

---

[1] ការវិភាគផ្អែកលើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាឯកសារផ្ទៃក្នុងនៃកិច្ចប្រជុំអន្តរក្រសួង សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១៤ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៤ ក្រោយពីទទួលបានយោបល់ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

អាជ្ញា និង បញ្ចូលសមាសភាពដែលមិនមែនជាចៅក្រម និង ព្រះរាជអាជ្ញា។ បេក្ខភាពនៃការបោះឆ្នោតទាំងអស់ត្រូវតែមិនស្ថិតនៅក្រោមចំណុះអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ។

- សមាជិកក្រុមប្រឹក្សាវិន័យ គួរតែកើតចេញពីការបោះឆ្នោតជ្រើសរើសប្រកបដោយភាពតំណាង ដោយចៅក្រម និង ព្រះរាជអាជ្ញា។
- អំណាចក្រសួងយុត្តិធម៌គួរតែត្រូវបានដកចេញពីគណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ តាមរយៈការបង្កើតឲ្យមានសមាសភាពមួយ ដែលកើតចេញពីការបោះឆ្នោតជ្រើសរើសប្រកបដោយភាពតំណាង ដោយចៅក្រម និង ព្រះរាជអាជ្ញា និង បញ្ចូលសមាសភាពដែលមិនមែនជាចៅក្រម និង ព្រះរាជអាជ្ញា។ បេក្ខភាពនៃការបោះឆ្នោតទាំងអស់ត្រូវតែមិនស្ថិតនៅក្រោមចំណុះអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ។
- អំណាចគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ទៅលើអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ គួរតែត្រូវបានដកចេញ និង ប្រគល់អំណាចនេះឲ្យទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាស្ថាប័នឯករាជ្យ។
- អំណាចចាត់ចែងរបស់ក្រសួងយុត្តិធម៌ទៅលើថវិការបស់សាលាជម្រះក្តី និង អយ្យការអមសាលាជម្រះក្តី គួរតែត្រូវបានដកចេញ និង ប្រគល់អំណាចនេះឲ្យទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាស្ថាប័នឯករាជ្យ។

## II. សាវតារ

- ឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") បានបង្កើតអំណាចតុលាការដែលឯករាជ្យពីអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ[2]។
- ខែមិថុនា ឆ្នាំ ២០០១ រដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង សេចក្តីព្រាងគម្រោងផែនការសកម្មភាពគោល[3]។
- ខែមិថុនា ឆ្នាំ ២០០៣ រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ[4]។
- ខែមិថុនា ឆ្នាំ ២០០៤ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌បានកែសម្រួលផែនការសកម្មភាពជាតារាងអាទិភាពរយៈពេលខ្លី (២០០៤-២០០៦) និង រយៈពេលវែង (២០០៤-២០០៨)។ ការរៀបចំឡើងវិញរចនាសម្ព័ន្ធឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃតុលាការ ត្រូវបានបញ្ចូលទៅក្នុងតារាងអាទិភាពរយៈពេលខ្លី[5]។

---

[2] *សូមមើល* មាត្រា ៥១ (ថ្មី) និង មាត្រា ១២៨ (ថ្មី) នៃរដ្ឋធម្មនុញ្ញ។

[3] មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) *ប្រទេសកម្ពុជា បញ្ហាដែលជ្រើសរើស* កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌៖ ការវិវត្តន៍ថ្មីៗ និង ការរំពឹងទុក ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៤ ទំព័រ ៦៩-៧៨។

[4] *សូមមើល* ដូចខាងលើ។

[5] *សូមមើល* ដូចខាងលើ។

- ឆ្នាំ ២០០៥ សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងវិស័យតុលាការត្រូវបានបង្វិលទៅវិញទៅមក រវាងគណៈរដ្ឋមន្ត្រី និង ក្រសួងយុត្តិធម៌[6]។
- ឆ្នាំ ២០១៣ លោក សូរីយ៉ា ប្រាសាទ ស៊ូបេឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានជំរុញឲ្យក្រសួងយុត្តិធម៌បង្កើនល្បឿនការអនុម័តសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងវិស័យតុលាការ[7]។
- ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១៤ សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងវិស័យតុលាការត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី[8]។
- ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងនៅក្នុងពិធីចែកសញ្ញាប័ត្រនៃសកលវិទ្យាល័យអាស៊ី-អឺរ៉ុប ថា "ដូចដែលចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ខុទ្ទការល័យគណៈរដ្ឋមន្ត្រីត្រូវដាក់ [សេចក្តីព្រាងច្បាប់] ទៅរដ្ឋសភាជាតិ មិនមែនទៅអង្គការមិនមែនរដ្ឋាភិបាលនោះទេ។ កុំទាមទារសិទ្ធិច្រើនពេក។ តាមពិតយើងបានស្តាប់យោបល់ច្រើនរួចមកហើយ ហើយយើងបានបញ្ចូលរួចអស់ហើយ [...] យើងមិនអាច [អនុម័តសេចក្តីព្រាងច្បាប់] នៅក្នុងអាណត្តិទី៤ នៃរាជរដ្ឋាភិបាល ហើយយើងបានខិតខំប្រឹងប្រែងអនុម័តសេចក្តីព្រាងច្បាប់នេះនៅក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាល ប៉ុន្តែ ពួកគេ [អង្គការសង្គមស៊ីវិល] បាននិយាយថា វាលឿនពេក ហើយយើងមិនបានពិភាក្សាជាមួយពួកគេ"[9]។
- ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៤ លោក ជាម យៀប ប្រធានគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា បានថ្លែងថា នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៤ ខាងមុខនេះ រដ្ឋសភាជាតិនៃប្រទេសកម្ពុជា នឹងលើកយកសេចក្តីព្រាងច្បាប់ទាំង ៣ មកពិភាក្សា មុននឹងធ្វើការអនុម័ត។ សេចក្តីព្រាងចំនួន ៣ នោះ រួមមាន (១) សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការមាន ៩១ មាត្រា ចែកជា ៨ ជំពូក (២) សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ៣១ មាត្រា និង ចែកចេញជា ៦ ជំពូក និង (៣) សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា មាន ១១១ មាត្រា និង ចែកចេញជា ៦ ជំពូក[10]។

---

[6] *សូមមើល* សារព័ត៌មាន ឌឹ ខេមបូឌា ដេលី *ភាពឯករាជ្យរងចំណោទដោយសាររចនាសម្ព័ន្ធតុលាការ ត្រូវបានរៀបចំជាថ្មី* ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៥។

[7] *សូមមើល* សារព័ត៌មាន ឌឹ ខេមបូឌា ដេលី *ស៊ូបេឌីជម្រុញការអនុម័តច្បាប់ក្នុងវិស័យតុលាការ* ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៣។

[8] *សូមមើល* វិទ្យុអាស៊ីសេរី (RFA) *ហ៊ុន សែន ព្រមាន NGOs មិនឲ្យជ្រៀតជ្រែកច្បាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌* ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៤។

[9] ការបកប្រែក្រៅផ្លូវការ។ *សូមមើល* ភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP news) *នាយករដ្ឋមន្ត្រី៖ ពង្រាងច្បាប់ទាក់ទងនឹងប្រព័ន្ធយុត្តិធម៌នឹងត្រូវបានអនុម័តដោយរដ្ឋសភាជាតិ* ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៤។

[10] *សូមមើល* សារព័ត៌មាន ដើមអំពិល *រដ្ឋសភា នឹងលើកយក សេចក្តីព្រាងច្បាប់ ចំនួន៣ ទាក់ទងតុលាការ មកពិភាក្សា នៅថ្ងៃទី២០ ឧសភា ខណៈមានការជំទាស់ ពីក្រុមអង្គការ* ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៤។

## III. ការវិភាគលើបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តន៍ល្អៗជាអន្តរជាតិ

គោលការណ៍ជាមូលដ្ឋាននៅក្នុងប្រទេសដែលប្រកាន់ខ្ជាប់ និង គោរពតាមលទ្ធិប្រជាធិបតេយ្យ គឺ គោលការណ៍បែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការឲ្យដាច់ និង ឯករាជ្យពីគ្នា[11]។ អំណាចតុលាការ គឺជាសសរទ្រូងមួយនៃសង្គមប្រជាធិបតេយ្យទំនើប។ ឯករាជ្យភាពតុលាការ គឺជាធាតុផ្សំចាំបាច់នៃនីតិរដ្ឋ និង ជាការធានាជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌។ ហេតុដូច្នេះហើយទើបរដ្ឋធម្មនុញ្ញ បានបង្កើតនូវអំណាចតុលាការមួយដែលជាអំណាចឯករាជ្យ ដើម្បីធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ[12]។ ឯករាជ្យគឺជាការដែលមិនមែនជាកម្មវត្ថុនៃការត្រួតត្រា ឬ ទទួលរងឥទ្ធិពលពីសំណាក់អ្នកណាម្នាក់[13]។ ដូច្នេះ អំណាចតុលាការ ជាអំណាចឯករាជ្យ ដរាបណាអំណាចនេះត្រូវបានបង្កើតឡើង និង ប្រព្រឹត្តិទៅដាច់ដោយឡែកពីអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ។ អំណាចនេះត្រូវបានការពារឲ្យរួចផុតពីការជ្រៀតជ្រែក និង ការជះឥទ្ធិពលដោយមិនត្រឹមត្រូវពីសំណាក់អំណាចទាំងពីរនេះ ដោយហេតុថា អំណាចតុលាការដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យលើការអនុវត្តន៍ច្បាប់ និង ការរំលោភអំណាចរបស់អំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ[14]។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ[15]។

សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា និង សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ <u>បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យភាពរបស់តុលាការ</u> ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ច្បាប់អន្តរជាតិ។ សេចក្តីព្រាងច្បាប់នេះបានដាក់អំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] ទៅក្នុងរចនាសម្ព័ន្ធរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

---

[11] មាត្រា ៥១ (ថ្មី) នៃរដ្ឋធម្មនុញ្ញ ៖ "ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស [...] អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។"

[12] *សូមមើល* មាត្រា ១២៨ (ថ្មី) នៃរដ្ឋធម្មនុញ្ញ។ មាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨៖ "មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា ពេញលេញ សុំឲ្យតុលាការឯករាជ្យ និង មិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និង ដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និង ភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។" មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ឆ្នាំ ១៩៦៦៖ "[...] ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និង មិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និង ជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬ លើសិទ្ធិ និង ករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី [...] ។"

[13] វចនានុក្រម Black Law បោះពុម្ពលើកទី ៧ ឆ្នាំ ១៩៩៩។

[14] *សូមមើល* អត្ថន័យនៃគោលការណ៍ "ត្រួតពិនិត្យ និង តុល្យភាព" (Check and Balances) អាចរកបាននៅលើគេហទំព័រ៖ http://www.merriam-webster.com/dictionary/checks%20and%20balances។

[15] មាត្រា ១៣២ (ថ្មី) នៃរដ្ឋធម្មនុញ្ញ។

ដែលជាស្ថាប័នមានតួនាទីធានាឯករាជ្យភាពតុលាការ ដូច្នេះនាំឲ្យក្រសួងយុត្តិធម៌មានអំណាចតាមផ្លូវច្បាប់ចូលរួមសម្រេចលើការតែងតាំង ដំឡើងឋានន្តរស័ក្តិ និង ដាក់វិន័យលើចៅក្រមដែលជាតួអង្គសំខាន់នៃអំណាចតុលាការ។ សេចក្តីព្រាងច្បាប់នេះបានផ្តល់លទ្ធភាពឲ្យអំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] គ្រប់គ្រងលើកិច្ចការរដ្ឋបាល និង ចាត់ចែងថវិការបស់សាលាជម្រះក្តី ដែលជាស្ថាប័នរបស់អំណាចតុលាការ។ ការធ្វើរបៀបនេះ គឺប៉ះពាល់ដល់ឯករាជ្យភាពតុលាការ ដែលមិនត្រឹមតែតម្រូវឲ្យចៅក្រមមិនលំអៀងប៉ុណ្ណោះទេ ថែមទាំងតម្រូវឲ្យសាធារណជនមើលឃើញថាអំណាចតុលាការនេះពិតជាត្រូវបានកាត់ផ្តាច់ចេញពីអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិពិតប្រាកដមែន ដែលអាចធ្វើឲ្យសង្គមទាំងមូលមានជំនឿលើអំណាចតុលាការ។

ដូច្នេះការវិភាគនេះដោយផ្អែកលើសេចក្តីព្រាងដែលយើងខ្ញុំបានឃើញ នឹងផ្តោតជាសំខាន់លើការត្រួតពិនិត្យលើអំណាច និង តួនាទីរបស់ក្រសួងយុត្តិធម៌ នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នៅក្នុងប្រព័ន្ធតុលាការទាំងមូល។[16]

## ១. សេចក្តីព្រាងច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

សេចក្តីព្រាងច្បាប់នេះមានគោលដៅបង្កើត និង កំណត់អំពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រដើម្បីធានាឯករាជ្យនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញ[17]។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានតួនាទីសម្រេច និង លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និង ការលុបឈ្មោះចៅក្រមទាំងអស់[18] ព្រមទាំងដាក់វិន័យចំពោះចៅក្រម[19]។

អនុលោមតាមការអនុវត្តន៍នៅថ្នាក់អន្តរជាតិ ដើម្បីធានាឲ្យបាននូវឯករាជ្យភាពតុលាការ គ្រប់សេចក្តីសម្រេចដែលជះឥទ្ធិពលលើការជ្រើសរើស តែងតាំង ដំឡើងឋានន្តរស័ក្តិ ឬ បញ្ឈប់ចៅក្រម ត្រូវធ្វើឡើងដោយអាជ្ញាធរឯករាជ្យពីអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ដែលនៅក្នុងនោះសមាជិកចំនួនយ៉ាងហោចណាស់ពាក់កណ្តាលជាចៅក្រម ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រមទាំងអស់ តាមរយៈនីតិវិធីដែលធានាបាននូវភាពតំណាងនៃអំណាចតុលាការទាំង

[16] សេចក្តីព្រាងទាំងបីនេះទទួលបានក្រៅផ្លូវការ ដោយសារតែរដ្ឋាភិបាល ឬរដ្ឋសភា ពុំបានផ្សព្វផ្សាយជាសាធារណៈនោះទេ។

[17] មាត្រា ១ នៃសេចក្តីព្រាងច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

[18] *ដូចខាងលើ* មាត្រា ១៨។

[19] *សូមមើល ដូចខាងលើ* មាត្រា ២០។

មូល[20]។ នៅក្នុងគោលបំណងនេះ អាជ្ញាធរឯករាជ្យនេះត្រូវតែមានស្វ័យភាពក្នុងការសម្រេចលើរបៀបដំណើរការរបស់ខ្លួន[21]។

**១.១. សេចក្តីព្រាងច្បាប់នេះបានដាក់បញ្ចូលអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] ទៅក្នុងរចនាសម្ព័ន្ធ ដំណើរការ និង ហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមានតួនាទីធានាឯករាជ្យភាពតុលាការ**

សេចក្តីព្រាងច្បាប់បានអនុញ្ញាតឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសមាជិករដ្ឋាភិបាល និង ជាភ្នាក់ងារនៃអំណាចនីតិប្រតិបត្តិ ធ្វើជាសមាជិកឧត្តមក្រុមប្រឹក្សាចៅក្រម (មាត្រា ៤) និង ជាអធិបតីនៃស្ថាប័ននេះ ក្នុងករណីដែលទទួលបានការចាត់តាំងពីព្រះមហាក្សត្រ ជាព្រះរាជតំណាងម្នាក់របស់ព្រះអង្គ ដើម្បីធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ៧)។ ចំណុចនេះក៏ជាក្តីបារម្ភរបស់ក្រុងអង្គការសង្គមស៊ីវិលក្នុងស្រុកចំនួន ១២ ដែលបានជួបប្រជុំពិភាក្សាគ្នាកាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤។

សេចក្តីព្រាងច្បាប់បានអនុញ្ញាតឲ្យសមាជិករដ្ឋសភា និង សមាជិកព្រឹទ្ធសភាដែលជាអំណាចនីតិប្បញ្ញត្តិ មានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ៤)។

ដោយហេតុថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអំណាចចេញសេចក្តីសម្រេចដែលជះឥទ្ធិពលលើអាជីពចៅក្រមដែលជាបុគ្គលឯករាជ្យ សមាជិកនៃស្ថាប័ននេះ <u>មិនអាចត្រូវបានតែងតាំង ឬ ជ្រើសតាំងដោយអំណាចនីតិប្បញ្ញត្តិ ឬ អំណាចនីតិប្រតិបត្តិឡើយ</u>[22]។ បន្ថែមពីលើនេះ ដើម្បីផ្តាច់ចេញពីអំណាចនយោបាយ បេក្ខភាពជាសមាជិកនេះត្រូវតែមិនមែនជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត និង សមាជិកនៃគណៈមេធាវី[23]។ ដូចគ្នានេះដែរ បេក្ខភាពសមាជិកជាចៅក្រម ឬ ព្រះរាជអាជ្ញាត្រូវតែជាបេក្ខជនដែល<u>មិនកាន់មុខតំណែងនៅក្នុងក្រសួងយុត្តិធម៌ និង/ឬ ស្ថាប័នរដ្ឋាភិបាលដទៃទៀតក្នុងរយៈពេលជាប់គ្នាចំនួន ០៥ (ប្រាំ) ឆ្នាំ</u> និង ជ្រើសរើសតាមរយៈការបោះ

---

[20] *សូមមើល* កថាខណ្ឌ ៣៨ នៃទស្សនៈលេខ ២ (២០០១) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីថវិកា និង ការគ្រប់គ្រងតុលាការ ដោយយោងលើប្រសិទ្ធិភាពតុលាការ និង មាត្រា ៦ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០១។ ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុបត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុប ដើម្បីពង្រឹងតួនាទីរបស់ចៅក្រមនៅទ្វីបអឺរ៉ុប។

[21] *សូមមើល* កថាខណ្ឌ ១៣ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។ យោងតាមកថាខណ្ឌ ២ នៃទស្សនៈលេខ ១០ នេះ ក្រុមប្រឹក្សាតុលាការមានតួនាទីការពារឯករាជ្យភាពរបស់ចៅក្រម ដូច្នេះក្រុមប្រឹក្សានេះមានតួនាទីដូចគ្នាទៅនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅប្រទេសកម្ពុជា គ្រាន់តែការប្រើពាក្យពេចន៍មានលក្ខណៈខុសគ្នា។

[22] *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣១។

[23] *សូមមើល ដូចខាងលើ* កថាខណ្ឌ ២៩។

ឆ្នោតប្រកបដោយភាពតំណាង ដោយចៅក្រម និង ព្រះរាជអាជ្ញាទូទាំងប្រទេស[24]។ សមាជិកជ្រើសរើសមិនគួរត្រូវបានដំឡើងឋានន្តរស័ក្តិ និង/ឬ ចាត់តាំងឲ្យទៅបំពេញមុខងារផ្សេងឡើយ នៅក្នុងអំឡុងពេលអាណត្តិរបស់ខ្លួន។

ជាពិសេសជាងនេះទៀត ក្រុមអង្គការសង្គមស៊ីវិលចំនួន ១២ និងក្រុមប្រទេសម្ចាស់ជំនួយចំនួន ២៣ ដែលបានចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃទី១៥ និងទី១៦ ខែឧសភានេះ បានសង្កត់ធ្ងន់ថាសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនត្រូវជាប់ពាក់ព័ន្ធនឹងគណៈបក្សនយោបាយណាមួយឡើយ។

ដើម្បីជៀសវាងនូវការកាពារផលប្រយោជន៍ផ្ទាល់ខ្លួន ការកាពារខ្លួន និង សំណព្វនិយមព្រមទាំងជាការឆ្លុះបញ្ចាំងនូវទស្សនៈចម្រុះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែមានសមាសភាពចម្រុះរវាងចៅក្រម-ព្រះរាជអាជ្ញា និង សមាជិកមានសមត្ថភាពផ្លូវច្បាប់ដទៃទៀត ដូចជាមេធាវី និងសាស្រ្តាចារ្យច្បាប់ជាដើម ដែលបោះឆ្នោតជ្រើសតាំងដោយគណៈកម្មការឯករាជ្យមួយ។ សមាជិកទាំងនេះមិនត្រូវជាអ្នកនយោបាយសកម្ម ឬ ជាសមាជិករដ្ឋាភិបាល ឬ ជាសមាជិកសភាឡើយ[25]។

សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែត្រូវបានជ្រើសរើស ដូចនៅក្នុងបទប្បញ្ញត្តិស្នើខាងក្រោម៖

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ៤៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ និង រួមមានសមាសភាពដូចខាងក្រោម៖<br>១. រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ជាសមាជិក<br>២. ប្រធានតុលាការកំពូល ជាសមាជិក<br>៣. អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក<br>៤. សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬ អតីតព្រះរាជអាជ្ញា ឬ ឥស្សរជន ដែលមានបទពិសោធន៍ការងារយ៉ាងតិច ១៥ ឆ្នាំ ឡើងទៅក្នុងវិស័យច្បាប់ ឬ តុលាការ | **មាត្រា ៤៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ និង រួមមានសមាសភាព ដូចខាងក្រោម៖<br>១. ចៅក្រមតុលាការកំពូល ០១ (មួយ) រូប ដែលមិនកាន់មុខតំណែងនៅក្នុងក្រសួងយុត្តិធម៌ និង/ឬ ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀតក្នុងរយៈពេលជាប់គ្នា ០៥ (ប្រាំ) ឆ្នាំ បោះឆ្នោតជ្រើសតាំងដោយចៅក្រមនៅតុលាការកំពូល។<br>២. ព្រះរាជអាជ្ញា [ទូទៅ] អមតុលាការកំពូល ០១ (មួយ) រូប បោះឆ្នោតជ្រើសតាំងដោយមហាអយ្យការអមតុលាការកំពូល។<br>៣. ចៅក្រមសាលាឧទ្ធរណ៍ ០១ (មួយ) រូប ដែលមិនកាន់មុខតំណែងនៅក្នុងក្រសួង |

[24] *សូមមើល អនុសាសន៍ស្តីពីសមាសភាពនៃក្រុមប្រឹក្សាតុលាការ* [B(a)(b)] ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) នៃទស្សនៈលេខ ១០ (២០០៧) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

[25] *សូមមើល ដូចខាងលើ* អនុសាសន៍ [B(c)] ។

| | |
|---|---|
| ៥. សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬ អតីតព្រះរាជអាជ្ញា ឬ ឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំឡើងទៅក្នុងវិស័យច្បាប់ ឬ តុលាការ<br>៦. សមាជិក ០១ (មួយ) រូប ជាចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់<br>៧. សមាជិក ០១ (មួយ) រូប ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ឬ ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និង នៅក្រសួងយុត្តិធម៌<br>៨. សមាជិក ០១ (មួយ) រូប ជាចៅក្រមពេញសិទ្ធិនៃសាលាដំបូងជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស<br>៩. សមាជិក ០១ (មួយ) ជាព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិ នៃអយ្យការអមសាលាដំបូងទូទាំងប្រទេស។ | យុត្តិធម៌ និង/ឬ ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀតក្នុងរយៈពេលជាប់គ្នា ០៥ (ប្រាំ) ឆ្នាំ បោះឆ្នោតជ្រើសតាំងដោយចៅក្រមនៅសាលាឧទ្ធរណ៍។<br>៤. ព្រះរាជអាជ្ញា [ទូទៅ] អមតុលាការកំពូល ០១ (មួយ) រូប បោះឆ្នោតជ្រើសតាំងដោយមហាអយ្យការអមសាលាឧទ្ធរណ៍។<br>៥. ចៅក្រមសាលាដំបូង ០១ (មួយ) រូប បោះឆ្នោតជ្រើសតាំងដោយចៅក្រម និង អយ្យការអមសាលាដំបូង។<br>៦. មេធាវី ០១ (មួយ) រូប ដែលមានបទពិសោធន៍ក្នុងវិស័យច្បាប់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ បោះឆ្នោតជ្រើសតាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។<br>៧. សមាជិកដទៃទៀត ដែលមិនមែនជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត និង សមាជិកនៃគណមេធាវី ជាស្ត្រី និង បុរស ក្នុងចំនួនស្មើគ្នាបោះឆ្នោតជ្រើសតាំងដោយគណៈកម្មការឯករាជ្យ។ |
| **មាត្រា ៥៖**<br>សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបាន [...] ។ | **មាត្រា ៥៖**<br>សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង។<br>សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនអាចត្រូវបានតំឡើងឋានន្តរសក្តិ ឬ ចាត់តាំង/ជ្រើសតាំងឲ្យទៅកាន់មុខងារផ្សេងទៀតឡើយ នៅក្នុងអំឡុងពេលអាណត្តិ [...] ។ |
| **មាត្រា ៧៖**<br>ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ | **មាត្រា ៧៖**<br>ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទ្រង់ចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គ |

| | |
|---|---|
| ព្រះអង្គ ឲ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន [...]។<br>ព្រះរាជតំណាងមិនចូលរួមក្នុងការធ្វើសេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ប៉ុន្តែ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ ប្រធានតុលាការកំពូលមានសិទ្ធិ ចូលរួមធ្វើសេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចសមាជិកដទៃទៀតដែរ។ | ដែលមិនមែនជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត និង សមាជិកនៃគណមេធាវី ឲ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ |

លើសពីនេះទៀត យោងតាមក្រុមអ្នកច្បាប់អន្តរជាតិ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពុំគួរអនុញ្ញាតឲ្យឈរឈ្មោះជាបន្តបន្ទាប់ទៀតនោះទេ។ ដូច្នេះវាក្យខណ្ឌទីពីរនៃមាត្រា ៥ នៃសេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលចែងថា *សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបាន [...]* គួរតែលុបចោល។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែមានទីតាំង អគ្គលេខាធិការដ្ឋាន ធនធាន និង សេរីភាពក្នុងការរៀបចំដំណើរការរបស់ខ្លួន ដោយមិនតម្រូវឲ្យរាយការណ៍សកម្មភាពរបស់ខ្លួនទៅអាជ្ញាធរនយោបាយណាមួយ ឬ អាជ្ញាធរដទៃទៀតឡើយ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែមានអំណាចដោយសេរីក្នុងការរៀបចំកិច្ចប្រជុំរបស់ខ្លួន និង ទំនាក់ទំនងដោយផ្ទាល់ជាមួយតុលាការ នៅក្នុងដំណើរការរបស់ខ្លួន។ ស្ថាប័ននេះគួរតែមានបុគ្គលិកទៅតាមតម្រូវការការងាររបស់ខ្លួន។[26] ចំណុចត្រូវបានគាំទ្រជាខ្លាំងដោយក្រុមសង្គមស៊ីវិលចំនួន ១២ ដែលបានចូលរួមប្រជុំកាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤។

អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែស្ថិតនៅ និង ដំណើរការដោយឯករាជ្យពីក្រសួងយុត្តិធម៌។ អគ្គលេខាធិការ និង អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយផ្ទាល់ដោយសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ ត្រូវតែងតាំងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយយោបល់នេះចងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឲ្យត្រូវតែអនុវត្តតាម។

| បទប្បញ្ញត្តិក្នុងព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ៨៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយស្ថិតនៅក្រោមរដ្ឋបាលកណ្ដាលនៃក្រសួងយុត្តិធម៌ [...] ។ | **មាត្រា ៨៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយ ដែលដំណើរការដោយឯករាជ្យ [...] ។ |

[26] *សូមមើល* កថាខណ្ឌ ៣៨ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្ដីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

| | |
|---|---|
| អគ្គលេខាធិការ និង អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម [...] ។ | អគ្គលេខាធិការ និង អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យោបល់នេះចងកាតព្វកិច្ចឲ្យអនុវត្តតាម [...] ។ |

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដែលអាចឲ្យស្ថាប័ននេះដំណើរការបានដោយរលូន។ ស្ថាប័ននេះគួរតែមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធ្វើដំណើរការ ដោយឯករាជ្យ និង ស្វ័យត ព្រមទាំងមានអំណាច និង សមត្ថភាពចរចា និង រៀបចំថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព[27]។ ក្រុមសង្គមស៊ីវិលចំនួន ១២ ដែលបានចូលរួមប្រជុំនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤ បានគាំទ្រ និងជំរុញជាខ្លាំងឲ្យមានភាពឯករាជ្យក្នុងការរៀបចំកិច្ចដំណើរការ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បន្ថែមលើនេះទៀត ក្រុមអ្នកច្បាប់អន្តរជាតិ និងក្រុមអង្គការសង្គមស៊ីវិល យល់ឃើញថា ដើម្បីធានាឯករាជ្យភាពនៃការបំពេញមុខងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់នេះគួរកែប្រែ ហើយត្រូវប្រគល់សមត្ថកិច្ចនេះដល់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលស្ថិតនៅដាច់ដោយឡែកពីក្រសួងយុត្តិធម៌ ជាអ្នកចាត់ចែង។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនត្រូវជាអណាប័កផ្ទេរសិទ្ធិ ឬ ជាប់ពាក់ព័ន្ធនឹងធនធានហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ព្រះមហាក្សត្រទ្រង់គួរតែផ្ទេរសិទ្ធិនេះឲ្យព្រះរាជតំណាងរបស់ព្រះអង្គ ឬ សមាជិកណាម្នាក់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏បាន។

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ១៥៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានកញ្ចប់ថវិការបស់ខ្លួន ដែលផ្គត់ផ្គង់ដោយថវិកាជាតិ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអាណាប័កផ្ទេរសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ | **មាត្រា ១៥៖**<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានកញ្ចប់ថវិការបស់ខ្លួន ដែលផ្គត់ផ្គង់ដោយថវិកាជាតិ។ ព្រះរាជតំណាង ឬ សមាជិកណាម្នាក់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអាណាប័កផ្ទេរសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ |

[27] *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣៧។

### ១.២. សេចក្តីព្រាងច្បាប់អនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានតែងតាំងដោយស្វ័យប្រវត្តិដោយមិនឆ្លងកាត់ការបោះឆ្នោតដោយស្ថាប័នមួយឯករាជ្យ

សេចក្តីព្រាងច្បាប់តម្រូវឲ្យក្រុមប្រឹក្សាវិន័យ ដែលមានតួនាទីដាក់វិន័យចៅក្រមស្ថិតនៅក្រោមអធិបតីភាពប្រធានតុលាការកំពូល និង ក្រុមប្រឹក្សាវិន័យដែលមានតួនាទីដាក់វិន័យព្រះរាជអាជ្ញា ស្ថិតនៅក្រោមអធិបតីភាពអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សមាជិកក្រុមប្រឹក្សាវិន័យនេះ គឺជាសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណីទាំងនេះ ព្រះមហាក្សត្រ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមក្នុងក្រុមប្រឹក្សាវិន័យទេ។ ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬ ព្រះរាជតំណាង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមប្រជុំក្នុងក្រុមប្រឹក្សាវិន័យនេះ (មាត្រា ២០)។

ក្រុមប្រឹក្សាចៅក្រមអឺរ៉ុបបានយល់ឃើញថា ការអន្តរាគមន៍ដោយ<u>អាជ្ញាធរឯករាជ្យ</u> ជាមួយនឹងនីតិវិធីដែលធានាឲ្យមានសិទ្ធិការពារក្តីពេញលេញ ជាការសំខាន់ជាពិសេសនៅក្នុងបញ្ហាវិន័យ [28] ។ ដូចគ្នានេះ គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពតុលាការ ក៏ធានាផងដែរលើនីតិវិធីនៃការដាក់វិន័យចំពោះចៅក្រម ឬព្រះរាជអាជ្ញា ប្រកបដោយយុត្តិធម៌មួយនៅចំពោះមុខស្ថាប័នឯករាជ្យ និងឥតលម្អៀង [29] ។ វាជាការសំខាន់ដែលចៅក្រមត្រូវទទួលបានការការពារនៅក្នុងនីតិវិធីវិន័យ ដោយធានាឲ្យមានការគោរពគោលការណ៍ឯករាជ្យភាពតុលាការ និង អនុវត្តដោយស្ថាប័នមួយដែលឯករាជ្យពីអំណាចនយោបាយណាមួយ។ ប្រមុខរដ្ឋ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ អ្នកតំណាងឲ្យអាជ្ញាធរនយោបាយដទៃទៀត មិនអាចចូលរួមនៅក្នុងអង្គភាពវិន័យឡើយ[30]។

ក្រុមប្រឹក្សាតុលាការ [ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម] ត្រូវបានផ្តល់ទំនុកចិត្តនៅក្នុងបញ្ហាក្រមសីលធម៌។ ប៉ុន្តែ ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ <u>ដំណាក់កាលដំបូង</u>នៃនីតិវិធីវិន័យគួរតែត្រូវបានដោះស្រាយដោយ<u>គណៈកម្មការវិន័យ</u> ដែលមានសមាសភាពតំណាងឲ្យចៅក្រម និង ព្រះរាជអាជ្ញា ដែល<u>បោះឆ្នោតជ្រើសតាំងដោយចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ ឬ ដោយ</u>

---

[28] *សូមមើល* កថាខណ្ឌ ៦០(b) នៃទស្សនៈលេខ ១ (២០០១) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីបទដ្ឋានទាក់ទងនឹងឯករាជ្យភាពតុលាការ និង គោលការណ៍មិនអាចដកចៅក្រមចេញបាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០១។

[29] *សូមមើល* កថាខណ្ឌទី ១៧ ដល់ ២០ នៃគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យតុលាការ ឆ្នាំ១៩៨៥។

[30] *សូមមើល* កថាខណ្ឌ ៦៣ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

ស្ថាប័នឯករាជ្យណាមួយ[31] និង មានសមាសភាពខុសពីសមាជិកក្រុមប្រឹក្សាតុលាការ [ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម][32]។

ផ្អែកតាមបទប្បញ្ញត្តិដែលបានស្នើនៅក្នុង មាត្រា ៤ ស្តីពីសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រធានតុលាការ និង អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនមែនជាអធិបតីនៃក្រុមប្រឹក្សាវិន័យ ដោយស្វ័យប្រវត្តិឡើយ។ សមាជិកនៃក្រុមប្រឹក្សាវិន័យគួរតែត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមួយឯករាជ្យ ឬ ដោយចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់។

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ២០៖**<br>ក្នុងមុខការដាក់វិន័យចំពោះចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល។ ក្នុងមុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជា ក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ក្នុងករណីទាំងនេះ ព្រះមហាក្សត្រ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមក្នុងក្រុមប្រឹក្សាវិន័យទេ។<br>ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬ ព្រះរាជតំណាង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមប្រជុំក្នុងក្រុមប្រឹក្សាវិន័យនេះ [...] ។ | **មាត្រា ២០៖**<br>ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និង ព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវកោះប្រជុំក្រុមប្រឹក្សាវិន័យ ដែលមានសមាសភាពកើតចេញពីការបោះឆ្នោតដោយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ ដោយចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់។<br>បេក្ខភាពនៃការបោះឆ្នោត ដែលជាចៅក្រម ឬ ព្រះរាជអាជ្ញាត្រូវតែមិនកាន់មុខតំណែងនៅក្នុងក្រសួងយុត្តិធម៌ និង/ឬ ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀតក្នុងរយៈពេលជាប់គ្នា ០៥ (ប្រាំ) ឆ្នាំ។ |

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្តើមគំនិតស៊ើបអង្កេត ដោយមិនចាំបាច់មានពាក្យបណ្តឹងជាមុន ចំពោះបញ្ហាទាក់ទងនឹងឯករាជ្យភាពនៃអាជ្ញាធរតុលាការ ក្រមសីលធម៌ និង វិន័យរបស់ចៅក្រម។ ចៅក្រមក៏អាចដាក់ពាក្យបណ្តឹងសុំការបកស្រាយផងដែរ ទាក់ទងនឹងសំណួរពាក់ព័ន្ធនឹងក្រមសីលធម៌។ វិសាលភាពនៃបណ្តឹង និង លក្ខខណ្ឌទទួលពាក្យបណ្តឹង គួរតែត្រូវបានចែង

[31] *សូមមើល* កថាខណ្ឌ ៧១ នៃទស្សនៈលេខ ៣ (២០០២) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីគោលការណ៍ និង វិធានគ្រប់គ្រងការប្រព្រឹត្តរបស់ចៅក្រម ជាពិសេសក្រមសីលធម៌ ឥរិយាបថដែលមានវិសមិតភាព និង ភាពមិនលំអៀង ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០២។

[32] *សូមមើល* កថាខណ្ឌ ៦៤ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

ច្បាស់លាស់ក្នុងច្បាប់ ដើម្បីជៀសវាងនូវបណ្ដឹងរំលោភបំពាន ដែលធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការ និង ជៀសវាងនូវការច្រានចោលបណ្ដឹងដោយគ្មានសម្អាងហេតុ និងសម្អាងច្បាប់។

ក្រុមអង្គការសង្គមស៊ីវិល និងក្រុមប្រទេសម្ចាស់ជំនួយ មានក្ដីបារម្ភជាខ្លាំងលើ ការដាក់បញ្ចូលក្រសួងយុត្តិធម៌ដែលជាភ្នាក់ងារមួយនៃអំណាចនីតិប្រតិបត្តិ ទៅក្នុងនីតិវិធីដោះស្រាយពាក្យបណ្ដឹងដាក់វិន័យលើចៅក្រម និង ព្រះរាជអាជ្ញា គឺធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់គោលការណ៍ឯករាជ្យភាពតុលាការ។

| បទប្បញ្ញត្តិក្នុងសេចក្ដីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ២៣៖**<br>ពាក្យបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និង ព្រះរាជអាជ្ញាត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ នៅក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់ឲ្យពិនិត្យ និង ស្រាវជ្រាវជាបឋមលើពាក្យបណ្ដឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងសម្រេចបញ្ជូនសំណុំរឿង ទៅក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។ | **មាត្រា ២៣៖**<br>ពាក្យបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និង ព្រះរាជអាជ្ញាត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្ដើមគំនិតស៊ើបអង្កេត ចំពោះបញ្ហាទាក់ទងនឹងឯករាជ្យភាពនៃអាជ្ញាធរតុលាការ ក្រមសីលធម៌ និង វិន័យរបស់ចៅក្រម។ |

សវនាការអំពីក្រមសីលធម៌ និង វិន័យ គួរតែត្រូវបានធ្វើឡើងជាសាធារណៈ ដើម្បីធានាបាននូវតម្លាភាព លើកលែងតែការធ្វើឡើងជាសាធារណៈនោះ ធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ជីវិតឯកជន និង កាលៈទេសៈពិសេសទាក់ទងនឹងផលប្រយោជន៍យុត្តិធម៌។ សេចក្ដីសម្រេចត្រូវតែប្រកាសជាសាធារណៈ ទោះបីជាសវនាការជាសាធារណៈ ឬ ជាសម្ងាត់ក៏ដោយ។

សេចក្ដីសម្រេចរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវមានសម្អាងហេតុ និងសម្អាងច្បាប់ មានកម្លាំងចាប់បង្ខំឲ្យអនុវត្តតាម និង អាចជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ[33]។

---

[33] *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣៩។ *សូមមើលផងដែរ* វិធាន ២០ នៃនៃគោលការណ៍គ្រឹះអង្គការសហប្រជាជាតិស្ដីពីភាពឯករាជ្យនៃអំណាចតុលាការ អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ស្ដីពីការបង្ការបទល្មើស និង ការប្រព្រឹត្តទៅលើជនល្មើស ប្រព្រឹត្តទៅនៅ មីលលែន (Milan) ពីថ្ងៃទី ២៦ ខែសីហា ដល់ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ១៩៨៥ និង គាំទ្រដោយសេចក្ដីសម្រេចនៃអង្គមហាសន្និបាត លេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ និង លេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ១៩៨៥។

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ២៥៖**<br>[…] ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យត្រូវធ្វើជាអសាធារណៈ។ ប្រធានក្រុមប្រឹក្សាវិន័យអាចអញ្ជើញបុគ្គលពាក់ព័ន្ធនានា ឲ្យចូលរួមក្នុងការប្រជុំរបស់ខ្លួនបាន បើយល់ឃើញថា ជាការចាំបាច់។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងបុគ្គលដែលចូលរួមប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ […] ។ | **មាត្រា ២៥៖**<br>[…] ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យត្រូវធ្វើជា សាធារណៈ។ លើកលែងតែការធ្វើឡើងជាសាធារណៈនោះ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ជីវិតឯកជន និង កាលៈទេសៈពិសេសទាក់ទងនឹងផលប្រយោជន៍យុត្តិធម៌ […]។ |
| **មាត្រា ២៦៖**<br>[…] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវមានសំអាងហេតុ និង សំអាងច្បាប់។ | **មាត្រា ២៦៖**<br>[…] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវមានសម្អាងហេតុ និង សម្អាងច្បាប់ មានកម្លាំងចាប់បង្ខំឲ្យអនុវត្តតាម និង អាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ។ សេចក្តីសម្រេចត្រូវតែប្រកាសជាសាធារណៈ ទោះបីជាសវនាការជាសាធារណៈ ឬជាសម្ងាត់ក៏ដោយ។ |

## ២. សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា

សេចក្តីព្រាងច្បាប់នេះ កំណត់អំពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា ព្រមទាំងគោលការណ៍ផ្សេងៗទៀតទាក់ទងនឹងចៅក្រម និង ព្រះរាជអាជ្ញា ក្នុងគោលបំណងធានាឯករាជ្យភាពនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញ[34]។

ឧត្តក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែមានសមត្ថកិច្ចនៅក្នុងការជ្រើសរើស តែងតាំង ដំឡើងឋានន្តរស័ក្តិចៅក្រម។ ការណ៍នេះត្រូវតែធ្វើឡើងដោយឯករាជ្យដាច់ខាតពីអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ[35]។ ក្រុមសង្គមស៊ីវិលជាតិ និងក្រុមអ្នកច្បាប់អន្តរជាតិ មានការជំទាស់ជាខ្លាំងក្នុងការដាក់ចៅក្រម និងព្រះរាជអាជ្ញាឲ្យស្ថិតក្រោមក្របខណ្ឌរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ (មាត្រា ៧) ដែលបញ្ហានេះធ្វើឲ្យប៉ះពាល់ដល់ការបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញា។

---

[34] មាត្រា ១ នៃ សេចក្តីពព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា។

[35] អនុសាសន៍ D(b) ស្តីពីអំណាចនៃក្រុមប្រឹក្សាតុលាការ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

**សេចក្តីព្រាងច្បាប់បានផ្តល់អំណាចឲ្យអំណាចនីតិប្រតិបត្តិ [ក្រសួងយុត្តិធម៌] មានឥទ្ធិពលលើការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រម និង ព្រះរាជអាជ្ញា**

សេចក្តីព្រាងច្បាប់នេះបានដាក់រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលជាភ្នាក់ងារនៃអំណាចនីតិប្រតិបត្តិទៅក្នុងតួនាទីមួយដែលចេញសេចក្តីសម្រេចលើការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រម និង ព្រះរាជអាជ្ញា។ បន្ថែមពីលើនេះ សមាជិកទាំងអស់របស់គណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រម និង ព្រះរាជអាជ្ញា កើតចេញពីការតែងតាំងដោយស្វ័យប្រវត្តិ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយការឲ្យគណៈកម្មការនេះ (មាត្រា ៣៣)។ មាត្រា ២៨ គួរតែចែងឲ្យច្បាស់ថា ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិរបស់ចៅក្រមគួរតែផ្អែកលើលក្ខខណ្ឌច្បាស់លាស់ រួមមាន សុចរិតភាព ឯករាជ្យភាព សមត្ថភាព បទពិសោធន៍ និងការប្តេជ្ញាធានាការពារនីតិរដ្ឋ[36]។

អាជ្ញាធរដែលមានអំណាចសម្រេចលើការជ្រើសរើស និង លើអាជីពចៅក្រម គួរតែឯករាជ្យពីរដ្ឋាភិបាល។ ដើម្បីធានាបាននូវឯករាជ្យភាព វិធានច្បាប់គួរតែធានាថា សមាជិករបស់អាជ្ញាធរនេះត្រូវបានជ្រើសរើសដោយតុលាការ ហើយថា អាជ្ញាធរនេះមានអំណាចសម្រេចលើវិធាននីតិវិធីដោយខ្លួនឯង[37]។

គោលការណ៍ឯករាជ្យភាពតុលាការ មិនត្រឹមតែការពារស្ថាប័ននេះឲ្យរួចផុតពីការជ្រៀតជ្រែក និង ឥទ្ធិពលពីខាងក្រៅប៉ុណ្ណោះទេ គោលការណ៍នេះក៏ការពារចៅក្រមផងដែរពីការទទួលរងឥទ្ធិពលពីខាងក្នុង ជាពិសេសពីសំណាក់អាជ្ញាធរតុលាការដែលមានអំណាចតាមឋានានុក្រម[38]។

គណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ គឺជាស្ថាប័នមួយដែលមានអំណាចចេញសេចក្តីសម្រេចលើការវិវត្តជឿនលឿននៃអាជីពរបស់ចៅក្រម និង ព្រះរាជអាជ្ញាម្នាក់ៗ។ ក្នុងករណីដែលក្រសួងយុត្តិធម៌ដែលជាភ្នាក់ងារមួយនៃអំណាចនីតិប្រតិបត្តិ ជាប្រធាននៃគណៈកម្មការនេះ ហើយមានអំណាចដំឡើងឋានន្តរស័ក្តិចៅក្រម និង ព្រះរាជអាជ្ញា ការធ្វើរបៀបនេះអាចនឹងធ្វើឲ្យកើតនូវភាពប្រថុយប្រថានថា ចៅក្រម និង ព្រះរាជអាជ្ញាដាក់ភាពមិនលម្អៀងរបស់ខ្លួនជាថ្នូរនឹងការដំឡើងឋានន្តរស័ក្តិ។

ដូច្នេះសមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិត្រូវតែជាចៅក្រម ព្រះរាជអាជ្ញា ឬ បេក្ខភាពមានសមត្ថភាពដទៃទៀត ដែលមិនមានចំណងទាក់ទងជាមួយអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ និង កើតចេញពីការបោះឆ្នោតជ្រើសតាំងដោយចៅក្រម និង ព្រះរាជអាជ្ញា ទាំងអស់។

---

[36] *សូមមើល* កថាខណ្ឌ ១៤ នៃសេចក្តីប្រកាសទីក្រុងស៊ីងវី (Singhvi Declaration)

[37] *សូមមើល* កថាខណ្ឌ ៣៦ នៃទស្សនៈលេខ ១ (២០០១) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីបទដ្ឋានទាក់ទងនឹងឯករាជ្យភាពតុលាការ និង គោលការណ៍មិនអាចដកចៅក្រមចេញបាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០១។

[38] *សូមមើល ដូចខាងលើ* កថាខណ្ឌ ៦៦។

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
|---|---|
| **មាត្រា ៣៣៖**<br>សមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរសក្តិ រួមមាន៖<br>- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១ (មួយ) រូប ប្រធាន<br>- អនុប្រធានតុលាការកំពូល ០១ (មួយ) រូប អនុប្រធាន<br>- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ០១ (មួយ) រូប អនុប្រធាន<br>- ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក<br>- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ភ្នំពេញ សមាជិក<br>- ប្រធានសាលាដំបូងរាជធានីភ្នំពេញ សមាជិក<br>- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ភ្នំពេញ សមាជិក<br>- អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លេខាធិការ។<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយការឲ្យគណៈកម្មការនេះ។ | **មាត្រា ៣៣៖**<br>សមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ ត្រូវកើតចេញពីការបោះឆ្នោតជ្រើសតាំងចៅក្រម និង ព្រះរាជអាជ្ញា ទាំងអស់។ បេក្ខភាពនៃការបោះឆ្នោត ដែលជាចៅក្រម ឬ ព្រះរាជអាជ្ញាត្រូវតែមិនកាន់មុខតំណែងនៅក្នុងក្រសួងយុត្តិធម៌ និង/ឬ ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀតក្នុងរយៈពេលជាប់គ្នា ០៥ (ប្រាំ) ឆ្នាំ។ បេក្ខភាពដទៃទៀតត្រូវតែមិនមែនជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត និង សមាជិកនៃគណមេធាវី។ |

លើសពីនេះទៀត កថាខណ្ឌទី ៣ នៃមាត្រា៥០ និងកថាខណ្ឌទី ៤ នៃមាត្រា ៩៦ នៃសេចក្តីព្រាងច្បាប់នេះ ដែលចែងថា ក្នុង*វិស័យនយោបាយ ចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រកាន់ជាច់ខាតនូវឥរិយាបថអព្យាក្រឹត* នៅពុំទាន់គ្រប់គ្រាន់ទេ ហើយក្រុមអង្គការសង្គមស៊ីវិល និងក្រុមប្រទេសម្ចាស់ជំនួយស្នើឲ្យមានការចែងពីទណ្ឌកម្មឲ្យបានច្បាស់លាស់ ប្រសិនជាចៅក្រម ឬព្រះរាជអាជ្ញាណាដែលមានជាប់ពាក់ព័ន្ធនឹងសកម្មភាពនយោបាយ។

ស្រដៀងគ្នានឹងចៅក្រមដែរ ព្រះរាជអាជ្ញាគួរមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្តែងមតិ ដូចជាតាមរយៈការផ្សព្វផ្សាយកិច្ចការរបស់ខ្លួនដោយមានការទទួលខុសត្រូវចំពោះក្រមសីលធម៌ ដោយមិនចាំបាច់ស្នើសុំការអនុញ្ញាតពីក្រសួងយុត្តិធម៌នោះទេ (មាត្រា៩៦)។[39] ប្រការនេះត្រូវបានគាំទ្រយ៉ាងពេញទំហឹងដោយក្រុមអង្គការសង្គមស៊ីវិល និងក្រុមប្រទេសម្ចាស់ជំនួយ។

---

[39] សូមមើលកថាខណ្ឌទី ៨ នៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា។

## ៣. សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

សេចក្តីព្រាងច្បាប់នេះមានគោលដៅ៖

- កំណត់អំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អង្គការតុលាការគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ទៅតាមជំនាញ
- រៀបចំការងារគ្រប់គ្រង ការងាររដ្ឋបាល និង ដំណើរការប្រព្រឹត្តទៅរបស់តុលាការ[40]។

### ៣.១. សេចក្តីព្រាងច្បាប់បានផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់

សេចក្តីព្រាងច្បាប់នេះបានផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ និង ចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជាកំណត់ (មាត្រា ១១)។

ក្រុមប្រឹក្សាតុលាការ [ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម] អាចមានសមត្ថកិច្ចទៅលើរដ្ឋបាល និង ការគ្រប់គ្រងនៃសាលាជម្រះក្តី ដើម្បីធានាបាននូវគុណភាពយុត្តិធម៌[41]។

ការកាត់ផ្តាច់រដ្ឋបាលតុលាការចេញពីក្រសួងយុត្តិធម៌ ធានាឲ្យមានការបែងចែកអំណាចពិតប្រាកដរវាងអំណាចតុលាការ និង អំណាចនីតិប្រតិបត្តិ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាស្ថាប័នមួយឯករាជ្យ និង មានតួនាទីធានាឯករាជ្យភាពតុលាការ គួរតែមានសមត្ថកិច្ចលើរដ្ឋបាលនៃសាលាជម្រះក្តី ដើម្បីអាចឲ្យស្ថាប័ននេះមានលទ្ធភាព និង មធ្យោបាយក្នុងការត្រួតពិនិត្យលើការអនុវត្តគោលការណ៍ឯករាជ្យភាពនេះនៅក្នុងគ្រប់ផ្នែកនៃស្ថាប័នតុលាការ។ ក្រុមសង្គមស៊ីវិល និង ក្រុមអ្នកច្បាប់អន្តរជាតិគាំទ្រឲ្យការដំណើរការរដ្ឋបាលរបស់តុលាការ ត្រូវស្ថិតដាច់ដោយឡែកពីក្រសួងយុត្តិធម៌ ឬរដ្ឋាភិបាល ដើម្បីធានាឯករាជ្យភាពដ៏ពេញលេញរបស់តុលាការ។

| បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ | បទប្បញ្ញត្តិស្នើ |
| --- | --- |
| **មាត្រា ១១៖**<br>ក្រសួងយុត្តិធម៌ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ [...]។<br>ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជា | **មាត្រា ១១៖**<br><u>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម</u>ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ [...]។<br>ក្នុងករណីចាំបាច់ <u>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម</u> អាចចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជា |

[40] មាត្រា ២ នៃសេចក្តីពព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

[41] អនុសាសន៍ (f) នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។

| | |
|---|---|
| កំណត់ រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និង សម្រេច [...]។ | កំណត់ [...]។ |

## ៣.២. សេចក្តីច្បាប់បានផ្តល់អំណាចឲ្យក្រសួងយុត្តិធម៌ចាត់ចែងលើថវិការបស់សាលាជម្រះក្តីទាំងអស់

សេចក្តីព្រាងច្បាប់តម្រូវឲ្យសាលាដំបូង និង អយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ (មាត្រា ៨៤)។ ករណីនេះមានការជំទាស់ជាខ្លាំងពីសំណាក់ក្រុមអង្គការសង្គមស៊ីវិល និង ក្រុមអ្នកច្បាប់អន្តរជាតិ ដោយសារតែមិនអាចធានាបាននូវឯករាជ្យភាពរបស់តុលាការ។

អនុលោមតាមគោលការណ៍គ្រឹះអង្គការសហប្រជាជាតិស្តីពីភាពឯករាជ្យនៃអំណាចតុលាការ វាជាករណីយកិច្ចរបស់រដ្ឋសមាជិកក្នុងការផ្តល់នូវធនធានគ្រប់គ្រាន់ ដើម្បីអាចឲ្យអំណាចតុលាការបំពេញមុខងាររបស់ខ្លួនបានត្រឹមត្រូវ[42]។ ហេតុដូច្នេះ ថវិការបស់សាលាជម្រះក្តី និង អយ្យការអមសាលាជម្រះក្តី គួរតែត្រូវបានរៀបចំឡើងដោយសាលាជម្រះក្តី ឬ អាជ្ញាធរមានជំនាញផ្នែករៀបចំថវិកា ដោយសហការជាមួយតុលាការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃភាពឯករាជ្យរបស់តុលាការ និង រដ្ឋបាលតុលាការ។

ទោះបីជាថវិការបស់សាលាជម្រះក្តី និង អយ្យការអមសាលាជម្រះក្តី គឺជាផ្នែកមួយនៃកញ្ចប់ថវិការដ្ឋក៏ដោយ ក៏ថវិកានេះមិនគួរត្រូវបានផ្លាស់ប្តូរតាមអំណាចនយោបាយឡើយ។ សេចក្តីសម្រេចលើការផ្តល់ថវិកាត្រូវតែធ្វើឡើងដោយគោរពយ៉ាងម៉ឺងម៉ាត់នូវឯករាជ្យភាពរបស់តុលាការ។ ការរៀបចំអនុម័តថវិកាតុលាការដោយសភា គួរតែរាប់បញ្ចូលការពិចារណាទៅលើគំនិតយោបល់របស់អំណាចតុលាការ[43]។

ក្រុមប្រឹក្សាចៅក្រមអឺរ៉ុបយល់ឃើញថា តុលាការអាចមានឯករាជ្យភាពពេញលេញ តែនៅក្នុងករណីដែលស្ថាប័ននេះមានថវិកាដាច់ដោយឡែក និង ចាត់ចែងគ្រប់គ្រងដោយស្ថាប័នមួយឯករាជ្យពីអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ដែលអាចជាក្រុមប្រឹក្សាតុលាការ [ឧត្តម

---

[42] វិធាន ៧ នៃគោលការណ៍គ្រឹះអង្គការសហប្រជាជាតិស្តីពីភាពឯករាជ្យនៃអំណាចតុលាការ អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ស្តីពីការបង្ការបទល្មើស និង ការប្រព្រឹត្តទៅលើជនល្មើស ប្រព្រឹត្តទៅនៅ មីលលែន (Milan) ពីថ្ងៃទី ២៦ ខែសីហា ដល់ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ១៩៨៥ និង គាំទ្រដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាត លេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ និង លេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ១៩៨៥។

[43] កថាខណ្ឌ ៧៣ នៃទស្សនៈលេខ ១០ (២០០៧) របស់ក្រុមប្រឹក្សានៃចៅក្រមអឺរ៉ុប (Consultative Council of European Judges) ស្តីពីក្រុមប្រឹក្សាតុលាការ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៧។ សូមមើលបន្ថែម កថាខណ្ឌទី ៣៧ នៃសេចក្តីថ្លែងការណ៍នៃគោលការណ៍ទីក្រុងប៉េកាំង។

ក្រុមប្រឹក្សានៃអង្គចៅក្រម] ឬ ស្ថាប័នឯករាជ្យផ្សេងទៀត[44]។ ក្រុមប្រឹក្សាចៅក្រមអឺរ៉ុបបានសង្កត់ធ្ងន់ថា ការប្រគល់អំណាចហិរញ្ញវត្ថុឲ្យដល់ក្រុមប្រឹក្សាតុលាការ [ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម] នឹងបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវរបស់ស្ថាប័ននេះចំពោះមុខអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ព្រមទាំងតុលាការ និង សាធារណៈជន[45] ជាពិសេសទាក់ទងនឹងប្រសិទ្ធភាព និង គុណភាពនៃការបំពេញមុខងាររបស់តុលាការ។

ការកំណត់អំពីលក្ខខណ្ឌនៃការផ្តល់ថវិកាទៅឲ្យសាលាជម្រះក្តីនានា និង សេចក្តីសម្រេចអំពីថាតើស្ថាប័នណាមួយគួរតែត្រួតពិនិត្យ និង រាយការណ៍អំពីប្រសិទ្ធភាពរបស់សាលាជម្រះក្តី គឺជាបញ្ហារសើប។ ក្រុមប្រឹក្សាចៅក្រមអឺរ៉ុបចាត់ទុកថា ក្រុមប្រឹក្សាតុលាការ [ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម] គួរតែមានសមត្ថកិច្ចពេញលេញលើបញ្ហានេះ[46]។

| **បទប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់** | **បទប្បញ្ញត្តិស្នើ** |
|---|---|
| **មាត្រា ៨៩៖**<br>សាលាដំបូង និង អយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ [...]។ | **មាត្រា ៨៩៖**<br>សាលាដំបូង និង អយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ <u>ដែលចាត់ចែង និង គ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម</u> [...]។ |

ក្រុមអង្គការសង្គមស៊ីវិល សហគមន៍អ្នកវិនិយោគិន និងក្រុមប្រទេសម្ចាស់ជំនួយ តាមរយៈកិច្ចប្រជុំនៅថ្ងៃទី១៥ និង ១៦ ខែឧសភា ក៏បានបង្ហាញអំពីការព្រួយបារម្ភបន្ថែមទៀតទាក់ទងនឹងបញ្ហាឯករាជ្យភាពរបស់តុលាការនេះដែរ ថែមទាំងលើកឡើងនូវការព្រួយបារម្ភដទៃទៀត និង បញ្ហាមួយចំនួនដែលគួរតែបញ្ចូលទៅក្នុងការពិចារណាទៅលើសេចក្តីព្រាងច្បាប់ ដូចខាងក្រោម៖

- គួរបញ្ជាក់ច្បាស់លាស់អំពីលក្ខណៈសម្បត្តិរបស់ជន ដែលអាចក្លាយជាទីប្រឹក្សាតុលាការពាណិជ្ជកម្ម និង សភាពាណិជ្ជកម្ម។
- គួរតែមានមាត្រាបញ្ជាក់អំពីដំណោះស្រាយ ក្នុងករណីដែលទីប្រឹក្សាដែលបានជ្រើសរើសមានទំនាស់ផលប្រយោជន៍ជាមួយគូភាគី។
- គួរតែបញ្ចូលតុលាការរដ្ឋបាល និង សភារដ្ឋបាលទៅក្នុងសេចក្តីព្រាងច្បាប់។

[44] *ដូចខាងលើ* កថាខណ្ឌ ៧៤។
[45] *ដូចខាងលើ* កថាខណ្ឌ ៧៥។
[46] *ដូចខាងលើ* កថាខណ្ឌ ៧៦។

## IV. សេចក្តីសន្និដ្ឋាន

ឯករាជ្យភាពរបស់តុលាការគឺជាក្តីបារម្ភរួមរបស់ក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ក្រុមអ្នកជំនួញ ព្រមទាំងម្ចាស់ជំនួយ ដោយហេតុថា ស្ថាប័នតុលាការដែលកំពុងដំណើរការបច្ចុប្បន្ន នេះទទួលរងនូវការរិះគន់ជាខ្លាំងថាមិនទាន់មានឯករាជ្យភាពនៅឡើយ។ នៅពេលដែលមើល ឃើញថា ស្ថានភាពតុលាការ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅពេលនេះទទួលរងនូវឥទ្ធិពល ពីគណៈបក្សនយោបាយកាន់អំណាចរួចទៅហើយនោះ សេចក្តីព្រាងច្បាប់ទាំងនេះត្រូវបានសង្គម ស៊ីវិល និងក្រុមប្រទេសម្ចាស់ជំនួយមើលឃើញថា សេចក្តីព្រាងច្បាប់ទាំងនេះហាក់ដូចជាតាក់តែង ដើម្បីគ្រប់គ្រងទ្វេរដងលើស្ថាប័នតុលាការ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ឯករាជ្យភាពរបស់តុលាការត្រូវតែធានាដោយរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ។ រដ្ឋាភិបាល និង ស្ថាប័នដទៃទៀត មានករណីយកិច្ចគោរព និង ប្រតិបត្តិតាមគោលការណ៍ឯករាជ្យ ភាពនៃអំណាចតុលាការ។ អាស្រ័យហេតុនេះ សេចក្តីព្រាងច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធនឹង វិស័យតុលាការ គួរតែត្រូវបានធ្វើឡើងដោយគិតទៅលើគោលការណ៍ឯករាជ្យភាពនេះជាគោល ដើម្បីធានាបានថា អំណាចតុលាការនឹងអាចធ្វើឲ្យអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ទទួលខុសត្រូវចំពោះមុខច្បាប់ និង ផ្តល់ការជំនុំជម្រះក្តីមួយដោយយុត្តិធម៌។ ឆ្លងតាមការវិភាគ ខាងលើ សេចក្តីព្រាងច្បាប់ទាំង ៣ មិនទាន់ឆ្លើយតបទៅនឹងគោលការណ៍ឯករាជ្យភាពរបស់ តុលាការដែលធានាដោយរដ្ឋធម្មនុញ្ញ និងគោលការណ៍ជាអន្តរជាតិនៅឡើយទេ ដូច្នេះទាមទារ ឲ្យមានការជជែក ត្រួតពិនិត្យ និង កែសម្រួលឡើងវិញជាមួយនឹងសង្គមស៊ីវិលជាតិ អន្តរជាតិ និង អ្នកជំនាញពាក់ព័ន្ធផ្សេងទៀត។

*********************